Save the Mekong
Our River Feeds Milions

# សេចក្តីព្រាងប្រកាសរបស់សម្ព័ន្ធសង្គ្រោះទន្លេមេគង្គ

*ទំនប់វារីអគ្គិសនីទន្លេមេគង្គ ជាការគំរាមកំហែងឆ្លងប្រទេសយ៉ាងខ្លាំងដល់សន្តិសុខស្បៀង និងប្រជាជននៅក្នុងតំបន់*

*អង្គការសង្គមស៊ីវិលសូមអំពាវនាវទៅនាយករដ្ឋមន្ត្រីគ្រប់ប្រទេសលុបចោលគម្រោងទំនប់វារីអគ្គិសនីទន្លេមេគង្គ*

នៅក្នុងឱកាសនៃកិច្ចប្រជុំលើកទី២០នៃក្រុមប្រឹក្សាគណកម្មការទន្លេមេគង្គ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៦ ខែមិថុនា នៅក្រុងបាងកក ប្រទេសថៃ សម្ព័ន្ធសង្គ្រោះទន្លេមេគង្គ សូមអំពាវនាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជា ប្រទេសឡាវ ប្រទេសថៃ និងប្រទេសវៀតណាម សហការគ្នាជាបន្ទាន់ដើម្បីរួមគ្នាដោះស្រាយការគំរាមកំហែងដល់សន្តិសុខស្បៀង និងប្រជាជននៅក្នុងតំបន់ដោយសារគម្រោងទំនប់វារីអគ្គិសនី១១នៅដងទន្លេមេគង្គ។ ថ្នាក់ដឹកនាំថ្នាក់តំបន់ទាំងអស់ត្រូវតែចាត់វិធានការលុបចោលគម្រោងវារីអគ្គិសនីទាំងនេះ រួមទាំងទំនប់វារីអគ្គិសនីសាយ៉ាប៊ូរី និងទំនប់ដុនសាហុងផង ដើម្បីធានាថា ការសម្រេចចិត្តនៅពេលក្រោយៗពាក់ព័ន្ធទន្លេដែលប្រើប្រាស់រួមគ្នានេះត្រូវបានធ្វើឡើងដោយផ្អែកលើចំណេះដឹងវិទ្យាសាស្ត្រ ផ្អែកលើការវាយតម្លៃផលប៉ះពាល់ឆ្លងប្រទេស និងការគោរពសិទ្ធិមនុស្សរបស់ប្រជាជាតិទាំងអស់ដែលរស់នៅតាមដងទន្លេ និងសិទ្ធិរបស់សាធារណជនចំពោះដំណើរការនៃការសម្រេចចិត្តដោយតម្លាភាព និងមានការចូលរួម។

ដោយសារទន្លេមេគង្គជាតំបន់ជលផលទឹកសាបធំបំផុតនៅក្នុងពិភពលោក ដូច្នេះទន្លេនេះចិញ្ចឹមប្រជាជនច្រើនជាង៦០លាននាក់ ដែលរស់នៅតាមអាងទន្លេនេះ រីឯជីវចម្រុះក្នុងទឹកជាប់ចំណាត់ថ្នាក់ទី២ បន្ទាប់ពីទន្លេអាមេហ្សូន។ ការតភ្ជាប់របស់ទន្លេ និងវដ្តទឹកជំនន់នៃទន្លេនេះមានសារសំខាន់ណាស់សម្រាប់រក្សាអេកូឡូស៊ីព្រៃព្រៃហូរ ហ្វ្រីព្រមទាំងជលផលយ៉ាងសម្បូរណ៍បែប និងតុល្យភាពដីល្បាប់ ដែលមានសារសំខាន់សម្រាប់ការដាំដំណាំស្បៀង នៅលើវាលរាបទឹកជំនន់យ៉ាងសម្បូរណ៍ជីវជាតិ។ ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រឆ្នាំ២០១០របស់គណកម្មការទន្លេមេគង្គ បានព្រមានអំពីការគំរាមកំហែងដល់បរិស្ថាន សង្គមនិងវប្បធម៌ យ៉ាងធ្ងន់ធ្ងរ

ដែលបណ្តាលមកពីគម្រោងវារីអគ្គិសនី អំពីការលំបាកនានាក្នុងការកាត់បន្ថយការខូចខាតដល់ជលផល អំពីកង្វះចំណេះដឹងមួយចំនួនដែលជាការរារាំងដល់ ការសម្រេចចិត្តគ្រប់ជ្រុងជ្រោយ។ ការសិក្សាជាបន្តបន្ទាប់មក ដូចជា របាយការណ៍ស្តីពីការវាយតម្លៃផលប៉ះពាល់ បានគូសបញ្ជាក់អំពីតម្រូវការសម្រាប់ការធ្វើផែនការវិស័យថាមពលឲ្យកាន់តែល្អប្រសើរ និងការប្រើជម្រើសថាមពលនិរន្តរភាពដើម្បីបំពេញតម្រូវការនៃកិច្ចអភិវឌ្ឍន៍របស់តំបន់។

វាសំខាន់ណាស់ដែលថា គណៈកម្មការទន្លេមេគង្គ និងប្រទេសដែលជាសមាជិករបស់គណៈកម្មការនេះ ត្រូវទទួលស្គាល់ឲ្យបានពេញលេញស្ថានភាពយ៉ាងធ្ងន់ធ្ងរដែលបង្កឡើងដល់ទន្លេមេគង្គហើយត្រូវរកដំណោះស្រាយជាបន្ទាន់ចំពោះការគំរាមកំហែងដែលបណ្តាលមកពីទំនប់វារីអគ្គិសនីតាមដងទន្លេមេគង្គ និងចំពោះការបរាជ័យរបស់គណៈកម្មការទន្លេមេគង្គខ្លួនឯង ដើម្បីធានាយ៉ាងមានប្រសិទ្ធភាពនូវការសម្រេចចិត្តថ្នាក់តំបន់ទាក់ទងនឹងគម្រោងទាំងនេះ។ ចាប់តាំងពីឆ្នាំ២០១០ រហូតមកដល់ពេលនេះ ការពិចារណាយ៉ាងល្អិតល្អន់នៅថ្នាក់តំបន់ថា តើត្រូវកសាងទំនប់វារីអគ្គិសនីកាត់ដងទន្លេមេគង្គ បានបណ្តាលឲ្យមានមហិច្ឆិតា និងបញ្ហាយ៉ាងធំនៅក្នុងដំណើរការនៃការគ្រប់គ្រងទន្លេដែលប្រើរួមគ្នានេះ និងធ្វើឲ្យមានតុល្យភាពតម្រូវការ និងការបារម្ភរបស់បណ្តាប្រទេសនៅទន្លេលើ និងទន្លេក្រោម។ ទោះបីជាមានសំណូមពរឲ្យធ្វើការសិក្សា និងពិគ្រោះយោបល់បន្ថែមពីរដ្ឋាភិបាលនៃប្រទេសកម្ពុជា ប្រទេសថៃ និងប្រទេសវៀតណាម ព្រមទាំងមានការអំពាវនាវពីប្រទេសកម្ពុជា និងប្រទេសវៀតណាមឲ្យផ្អាករយៈពេល១០ឆ្នាំក្នុងការសម្រេចចិត្តក៏ដោយ ក៏ដំណើរការនៃការសាងសង់ទំនប់វារីអគ្គិសនីសាយ៉ាប៊ូរី និងទំនប់ដុនសាហុង ដំណើរការរួចទៅហើយនៅក្នុងប្រទេសឡាវ។ ការបរាជ័យរបស់គណៈកម្មការទន្លេមេគង្គក្នុងការធានាឲ្យមានកិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាលទាំងបួនប្រទេស ទៅតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងទន្លេមេគង្គឆ្នាំ១៩៩៥ នាំឲ្យមានហានិភ័យនៃវិបត្តិកាន់តែធ្ងន់ធ្ងរ នៅពេលដែលមានបញ្ហាផលប៉ះពាល់ឆ្លងដែនដោយសារទំនប់វារីអគ្គិសនី។

រយៈពេលប្រាំមួយឆ្នាំកន្លងទៅនេះ ការជំទាស់ជាសាធារណៈយ៉ាងច្រើនចំពោះគម្រោងទំនប់វារីអគ្គិសនីកាត់ដងទន្លេមេគង្គ ត្រូវធ្វើឡើងទាំងថ្នាក់ជាតិ ថ្នាក់តំបន់ និងនៅលើឆាកអន្តរជាតិ តាមរយៈការដាក់ញត្តិ និងលិខិតជាច្រើនទៅរដ្ឋាភិបាលនៅក្នុងតំបន់ និងគណៈកម្មការ

ទន្លេមេគង្គ ប៉ុន្តែទោះជាយ៉ាងនេះក្តី ក៏ដំណើរការនៃគម្រោងសាងសង់នៅបន្តអនុវត្តដោយពុំមានឈប់ឡើយ។

សម្ព័ន្ធសង្គ្រោះទន្លេមេគង្គ បន្តជំហររបស់ខ្លួនក្នុងការជំទាស់គម្រោងសាងសង់ជាបន្តបន្ទាប់ទាំង១១គម្រោង ដោយសារតែផលប៉ះពាល់ឆ្លងដែនមិនអាចប្រកែកបាន ដែលបណ្តាលមកពីគម្រោងនេះទៅលើ ទន្លេជានិមិត្តរូបដែលប្រជាជនរាប់លាននាក់នៅក្នុងតំបន់ពឹងអាស្រ័យសម្រាប់ជាសរសៃឈាម និងរបរចិញ្ចឹមជីវិតរបស់ពួកគាត់។ គេមិនអាចធ្វើសេចក្តីសម្រេចចិត្តគ្រប់ជ្រុងជ្រោយពាក់ព័ន្ធនឹងគម្រោងសាងសង់ទំនប់វារីអគ្គិសនីបានទេ ប្រសិនបើ គម្រោងទាំងនោះមិនត្រូវបានបញ្ឈប់ជាបន្ទាន់ និងធ្វើការសិក្សាយ៉ាងចាំបាច់ដើម្បីវាយតម្លៃអំពីផលប៉ះពាល់ទាំងស្រុងទូទាំងតំបន់។ ដោយសារតែមានការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរ ដែលបណ្តាលមកពីទំនប់វារីអគ្គិសនីតាមដងទន្លេមេគង្គ ដូច្នេះហើយ អ្នកដឹកនាំថ្នាក់តំបន់ ត្រូវតែទទួលខុសត្រូវ និងធ្វើឲ្យប្រទេសនីមួយៗមានការទទួលខុសត្រូវ ដើម្បីចាត់វិធានការចរចាជាបន្ទាន់។

យើងខ្ញុំសូមអំពាវ សុំឲ្យអ្នកដឹកនាំថ្នាក់តំបន់ មេត្តាចាត់អាទិភាពក្នុងការគិតពិចារណាវែងឆ្ងាយចំពោះគម្រោងទំនប់វារីអគ្គិសនីតាមដងទន្លេមេគង្គ និងធានាថា នឹងត្រូវបានលើកមកពិភាក្សាជាចំណុចសំខាន់អំឡុងពេលនៃកិច្ចប្រជុំក្រុមប្រឹក្សាក្នុងសប្តាហ៍នេះ។ ទន្ទឹមនឹងនេះ យើងខ្ញុំក៏សូមទាមទារឲ្យរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ បញ្ឈប់ជាបន្ទាន់នូវគម្រោងសាងសង់ទំនប់វារីអគ្គិសនីសាយ៉ាប៊ូរី និងដុនសាហុង ព្រមទាំងគោរពសិទ្ធិរបស់ប្រជាជននៃប្រទេសជិតខាងដែលរស់នៅតាមដងទន្លេនេះ និងប្រជាជនទាំងអស់ដែលពឹងអាស្រ័យលើទន្លេ និងព្រមធនធានពីទន្លេ ដោយធ្វើការពិគ្រោះយោបល់យ៉ាងល្អិតល្អន់ជាមួយប្រជាជនទាំងអស់ដែលមានសិទ្ធិពេញលេញទទួលផលពីទន្លេទៅតាមច្បាប់អន្តរជាតិ។ យើងទាំងអស់គ្នាត្រូវតែរួមគ្នាសង្គ្រោះទន្លេមេគង្គ ព្រោះវាជាពេលវេលាយ៉ាងសំខាន់បំផុត។

អនុម័តដោយ៖

Both Ends, The Netherlands
Cambodia Volunteers for Society, Cambodia
Cambodian Rural Development Team, Cambodia
Chiang Kong Conservation Group, Thailand
Community Economic Development, Cambodia
Community Resource Centre, Thailand

Corner House, United Kingdom
Earthrights International, USA
Ecosun Cambodia, Cambodia
Fisheries Action Coalition Team, Cambodia
Focus on the Global South, Thailand
Green ID, Vietnam
International Rivers, USA
Living River Siam, Thailand
Jesuit Service Cambodia, Cambodia
Mangrove Action Project, Thailand
Mekong Monitor Tasmania, Australia
Mekong Watch, Japan
Mlup Prum Viheathor Center, Cambodia
My Village, Cambodia
Network of Thai People in Eight Mekong Provinces, Thailand
NGO Forum on Cambodia, Cambodia
PanNature, Vietnam
Ponlok Khmer, Cambodia
Probe International, Canada
REDD-Monitor
Towards Ecological Recovery and Regional Alliance, Thailand
Vietnam Rivers Network, Vietnam
WARECOD, Vietnam
3S Rivers Protection Network, Cambodia